# សន្និសិទអង្គការពលកម្មអន្តរជាតិ

International
Labour
Organization

Organisation
internationale
du Travail

Organizactión
Internacional
del Trabajo



# អនុសញ្ញាលេខ ១៦៩

## ស្តីពី

## ជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធ

## នៅក្នុងរដ្ឋឯករាជ្យ

Khmer.qxp 8/31/2006 9:59 AM Page 1

# សន្និសិទអង្គការពលកម្មអន្តរជាតិ

# អនុសញ្ញាលេខ ១៦៩

## ស្តីពី

## ជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធ

## នៅក្នុងរដ្ឋឯករាជ្យ

**គំរោងកម្មវិធីផ្សព្វផ្សាយគោលនយោបាយ**
**របស់អង្គការពលកម្មអន្តរជាតិស្តីពី**
**ជនជាតិដើមភាគតិចនិងជនកុលសម្ព័ន្ធ** (PRO 169)

International Labour Office Geneva
Tel: + 41 (0) 22 799 7556
Fax: + 41 (0) 22 799 6344
E-mail: PRO169@ilo.org

**គំរោងអភិវឌ្ឍន៍សិទ្ធជនជាតិ**
**ដើមភាគតិចនៅកម្ពុជា** (ITP)

Tel.: (855) +23 - 220 817, 994 209
Fax: (855) +23 221 536
Email: sophorn.iloitp@online.com.kh
Phnom Penh, Cambodia

**បកប្រែជាភាសាខ្មែរក្រៅផ្លូវការ ៖**
**លោក សេក សោភ័ណ**
ប្រធានគំរោងប្រចាំប្រទេសកម្ពុជា
គំរោងអភិវឌ្ឍន៍សិទ្ធិជនជាតិដើមភាគតិច
អង្គការពលកម្មអន្តរជាតិ (ILO)

**ពិនិត្យផ្ទៀងផ្ទាត់ការបកប្រែ ៖**
ការិយាល័យឧត្តមស្នងការសិទ្ធមនុស្សអង្គការ
សហប្រជាជាតិ ប្រចាំប្រទេសកម្ពុជា

Khmer.qxp 8/31/2006 9:59 AM Page 2

## មហាសន្និសិទនៃអង្គការពលកម្មអន្តរជាតិ

**ត្រូវបានកោះប្រជុំ** នៅទីក្រុងហ្សឺណែវ ដោយស្ថាប័នអភិបាលកិច្ចនៃការិយាល័យអង្គការពលកម្មអន្តរជាតិ និងបានជួបប្រជុំនៅក្នុងសម័យប្រជុំលើកទី៧៦ របស់ខ្លួន នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៨៩ និង-

***កត់សំគាល់ឃើញថា*** បទដ្ឋានអន្តរជាតិដែលមានចែងនៅក្នុងអនុសញ្ញា និងអនុសាសន៍ ស្តីពីប្រជាពលរដ្ឋ ជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធ ឆ្នាំ១៩៥៧ និង-

***រំលឹកឡើងវិញ*** អំពីលក្ខខណ្ឌនៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងលិខិតុបករណ៍ អន្តរជាតិនានា ស្តីពីការការពារមិនឱ្យមានការរើសអើង និង-

***យល់ឃើញថា*** ការអភិវឌ្ឍន៍ទាំងឡាយដែលកើតមានកន្លងមកនៅក្នុងច្បាប់អន្តរជាតិចាប់តាំង ពីឆ្នាំ១៩៥៧ ព្រមទាំងការអភិវឌ្ឍន៍នៅក្នុងស្ថានភាពនៃជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធនៅ ក្នុងតំបន់នានាលើពិភពលោក បានធ្វើឱ្យមានភាពសមស្រប ក្នុងការអនុម័តបទដ្ឋានអន្តរជាតិថ្មីលើប្រធានបទនេះ ដែលមានគោលដៅជៀងវាង ការដាក់បញ្ចូលគ្នានូវបទដ្ឋានចាស់ៗទាំងឡាយដែលមានពីមុនមក និង-រ

***ទទួលស្គាល់*** បំណងប្រាថ្នារបស់ប្រជាជនទាំងនេះ ក្នុងការប្រើប្រាស់សិទ្ធិគ្រប់គ្រងស្ថាប័នរបស់ខ្លួនដោយផ្ទាល់ របៀបរបបរស់នៅ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការប្រកាន់ខ្ជាប់ និងការអភិវឌ្ឍន៍អត្តសញ្ញាណភាសា និង សាសនារបស់ខ្លួន នៅក្នុងក្របខ័ណ្ឌរដ្ឋ ទាំងឡាយដែលពួកគេរស់នៅ និង-

***កត់សំគាល់ឃើញថា*** នៅក្នុងតំបន់ជាច្រើនលើពិភពលោក ប្រជាជនទាំងនេះ

Khmer.qxp 8/31/2006 9:59 AM Page 3

មិនអាចប្រើប្រាស់សិទ្ធិ មនុស្សជាមូលដ្ឋានរបស់ខ្លួន ក្នុងកំរិតមួយដូចគ្នានឹងប្រជាពលរដ្ឋដទៃទៀតនៅក្នុងរដ្ឋដែលខ្លួនរស់នៅឡើយ ហើយ ថាច្បាប់ តម្លៃ ទំនៀមទម្លាប់ និងទស្សនៈរបស់គេ ជារឿយៗត្រូវបានរលប់រលាយបន្តិចម្តងៗ និង-

***អំពាវនាវ***ឱ្យយកចិត្តទុកដាក់ដល់ការរួមវិភាគទានដាច់ដោយឡែកនៃជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធចំពោះ វប្បធម៌ផ្សេងៗគ្នា និងភាពសុខដុមរមនាផ្នែកសង្គមនិងបរិស្ថានវិទ្យានៃមនុស្សជាតិ នឹងចំពោះកិច្ចសហប្រតិបត្តិការ និងការយោគយល់គ្នាជាអន្តរជាតិ និង-

***កត់សំគាល់ឃើញថា*** បទបញ្ញត្តិទាំងឡាយខាងក្រោមនេះ ត្រូវបានរៀបចំឡើងដោយមានកិច្ចសហប្រតិ បត្តិការពីអង្គការសហប្រជាជាតិ អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ អង្គការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌នៃអង្គការសហប្រជាជាតិ និងអង្គការសុខភាពពិភពលោក ព្រមទាំងវិទ្យាស្ថានអន្តរអា មេរិកកាំង-ឥណ្ឌា នៅក្នុងកំរិតសមស្របទៅតាមវិស័យរៀងៗខ្លួន ហើយកត់សំគាល់ឃើញថាមានការស្នើសុំឱ្យបន្ត កិច្ចសហប្រតិបត្តិការនេះ ដើម្បីលើកស្ទួយ និងធានាដល់ការអនុវត្តន៍បទបញ្ញត្តិទាំងនេះ និង-

***បានសម្រេច*** លើការអនុម័តសេចក្តីស្នើមួយចំនួនពាក់ព័ន្ធនឹងការពិនិត្យសើរើឡើងវិញនូវផ្នែកខ្លះ នៃអនុសញ្ញាស្តីពីប្រជាពលរដ្ឋជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធឆ្នាំ១៩៥៧ (លេខ១០៧)ដែលស្ថិតក្នុងរបៀបវារៈ ទី៤ នៃសម័យប្រជុំ និង-

បានកំណត់ថាសេចក្តីស្នើទាំងនេះនឹងត្រូវយកតាមទំរង់នៃអនុសញ្ញាអន្តរជាតិក្នុងការពិនិត្យសើរើឡើងវិញ នូវអនុសញ្ញាស្តីពីប្រជាពលរដ្ឋជនជាតិដើមភាគតិចនិងជនកុលសម្ព័ន្ធឆ្នាំ១៩៥៧-

***អនុម័ត***អនុសញ្ញាខាងក្រោមនេះ នៅថ្ងៃទីម្ភៃប្រាំពីរ ខែមិថុនា ឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបប្រាំបួន ដែលអាចហៅបានថា **អនុសញ្ញាស្តីពីជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធឆ្នាំ១៩៨៩ :**

## ផ្នែកទី ១
## គោលនយោបាយទូទៅ

**មាត្រា ១**

១-អនុសញ្ញានេះអនុវត្តចំពោះ :

ក-ជនកុលសម្ព័ន្ធនៅក្នុងប្រទេសឯករាជ្យដែលលក្ខខណ្ឌផ្នែកសង្គមកិច្ច វប្បធម៌ និងសេដ្ឋកិច្ចរបស់គេ ធ្វើ ឱ្យពួកគេមានលក្ខណៈខុសប្លែកពីសហគមន៍ជាតិដទៃទៀត ហើយឋានៈរបស់ពួកគេត្រូវបានកំណត់ ទាំងស្រុង ឬផ្នែកខ្លះទៅតាមទំនៀមទំលាប់ ឬប្រពៃណីផ្ទាល់ខ្លួនរបស់គេ ឬដោយច្បាប់ ឬលិខិតបទដ្ឋាន ពិសេស ។

ខ- ប្រជាជនទាំងឡាយក្នុងប្រទេសឯករាជ្យ ដែលត្រូវបានចាត់ទុកថាជាជនជាតិដើមភាគតិច ដោយសារតែគេមានដើមកំណើតមកពីប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេស ឬក្នុងតំបន់ភូមិសាស្ត្រនៃប្រទេសនោះ នៅក្នុងអំឡុងពេលនៃការវាយដណ្តើមយកកាន់កាប់ ឬការធ្វើអាណានិគម ឬការបង្កើតព្រំដែនរដ្ឋបច្ចុប្បន្ន ហើយដោយមិនគិតដល់ឋានៈខាងផ្លូវច្បាប់របស់គេ គឺជាជនដែលរក្សាបន្តបានទាំងអស់ ឬផ្នែកខ្លះនៃ ស្ថាប័នសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ និងនយោបាយរបស់ខ្លួន ។

Khmer.qxp 8/31/2006 9:59 AM Page 5

២-ស្វ័យអត្តសញ្ញាណកម្ម (ការទទួលស្គាល់អត្តសញ្ញាណផ្ទាល់ខ្លួនដោយខ្លួនឯង) ថាជាជនជាតិដើមភាគតិច ឬជនកុលសម្ព័ន្ធ ត្រូវបានចាត់ទុកថា ជាលក្ខណៈវិនិច្ឆ័យមូលដ្ឋានសំរាប់កំណត់ក្រុមទាំងឡាយដែលត្រូវ អនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ ។

៣- ការប្រើពាក្យ "ប្រជាជន"នៅក្នុងអនុសញ្ញានេះ មិនត្រូវបានបកស្រាយថា មានការប៉ះពាល់ណាមួយដល់ សិទ្ធិ ដែលភ្ជាប់ទៅនឹងពាក្យក្រោមច្បាប់អន្តរជាតិឡើយ ។

**មាត្រា ២**

១-រដ្ឋាភិបាលនានា ត្រូវទទួលខុសត្រូវក្នុងការបង្កើតផែនការសកម្មភាពដែលមានការសម្របសម្រួល និងជាប្រព័ន្ធ ដោយមានការចូលរួមពីប្រជាជនពាក់ព័ន្ធ ដើម្បីការពារសិទ្ធិរបស់ប្រជាជនទាំងនេះ និងដើម្បីធានាឱ្យមានការ គោរពបូរណភាពរបស់ខ្លួន ។

២-សកម្មភាពនោះត្រូវរួមបញ្ចូលនូវវិធានការនានា ដើម្បី :

ក-ធានាថាសមាជិកនៃប្រជាជនទាំងនេះទទួលបានអត្ថប្រយោជន៍ស្មើភាពគ្នាពីសិទ្ធិ និងឱកាសដែលច្បាប់ ជាតិ និងលិខិតបទដ្ឋាននានា ផ្តល់ឱ្យសមាជិកផ្សេងៗទៀតនៃពលរដ្ឋទូទៅ ។

ខ-ជំរុញឱ្យទទួលបានយ៉ាងពេញលេញនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជាជនទាំងនេះ ដោយគោរពចំពោះអត្តសញ្ញាណសង្គម និងវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងស្ថាប័នរបស់ខ្លួន ។

គ-ជួយសមាជិកនៃប្រជាជនពាក់ព័ន្ធ ដើម្បីបំបាត់គំលាតខាងសេដ្ឋកិច្ចសង្គម ដែលអាចមានរវាងជនជាតិដើមភាគតិច និងសមាជិកដទៃទៀតនៃសហគមន៍ជាតិ ដែលមានលក្ខណៈស្របគ្នាជាមួយនឹងបំណងប្រាថ្នា និងរបៀបរបបរស់នៅរបស់ខ្លួន។

Khmer.qxp 8/31/2006 9:59 AM Page 6

## មាត្រា ៣

១-ជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធមានសិទ្ធិទទួលបានវិធានការពេញលេញនៃសិទ្ធិមនុស្ស និងសេរីភាពជា មូលដ្ឋានដោយគ្មានការរំខាន ឬការរើសអើងឡើយ ។ បទបញ្ញត្តិនៃអនុសញ្ញានេះត្រូវអនុវត្ត ដោយគ្មានការរើស អើងចំពោះសមាជិកជាបុរស និងជាស្ត្រីនៃប្រជាជនទាំងនេះឡើយ ។

២- គ្មានទំរង់នៃការប្រើប្រាស់កម្លាំង ឬការបង្ខិតបង្ខំណាមួយ ត្រូវបានប្រើដោយបំពានលើសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋានរបស់ប្រជាជនពាក់ព័ន្ធឡើយ រួមទាំងសិទ្ធិមួយចំនួនដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

## មាត្រា ៤

១-ត្រូវអនុម័តវិធានការពិសេស តាមការចាំបាច់ ដើម្បីធានាការពារមនុស្ស ស្ថាប័ន ទ្រព្យសម្បត្តិ ការងារ វប្បធម៌ និងបរិស្ថាននៃប្រជាជនពាក់ព័ន្ធ ។

២-វិធានការពិសេសនេះមិនត្រូវផ្ទុយទៅនឹងឆន្ទៈសម្តែងមតិដោយសេរីរបស់ប្រជាជនពាក់ព័ន្ធឡើយ ។

៣-ការទទួលបានសិទ្ធិទូទៅជាពលរដ្ឋ ដោយគ្មានការរើសអើង មិនត្រូវធ្វើឱ្យខូចខាតដោយសារវិធានការពិសេស នេះឡើយ ទោះជាក្នុងរូបភាពណាក៏ដោយ ។

## មាត្រា ៥

ក្នុងការអនុវត្តន៏បទបញ្ញត្តិនៃអនុសញ្ញានេះ :

ក- តម្លៃ និងការប្រតិបត្តិផ្នែកសង្គម វប្បធម៌ សាសនា និងស្មារតីរបស់ប្រជាជនទាំងនេះត្រូវបានទទួលស្គាល់ និងការពារ ហើយត្រូវមានការគិតគូរត្រឹមត្រូវចំពោះចរិតនៃបញ្ហាដែលពួកគេប្រឈមមុខ ជាក្រុម ឬជាបុគ្គល

ខ- ត្រូវគោរព បូរណភាពនៃតម្លៃ ការប្រតិបត្តិ និងស្ថាប័នរបស់ប្រជាជនទាំងនេះ

គ- គោលនយោបាយដែលមានគោលដៅសំរាលការលំបាកដែលប្រជាជនទាំងនេះធ្លាប់ជួបប្រទះ ក្នុងការប្រឈមមុខនឹងលក្ខខណ្ឌថ្មីនៃជីវភាពរស់នៅ និងការងារ ត្រូវបានអនុម័ត ដោយមានការចូលរួម និងការសហការពីប្រជាជនដែលទទួលរងផលប៉ះពាល់ ។

## មាត្រា ៦

១- ក្នុងការអនុវត្តនីបទបញ្ញត្តិនៃអនុសញ្ញានេះ រដ្ឋាភិបាលត្រូវ :

ក-ពិគ្រោះយោបល់ជាមួយប្រជាជនពាក់ព័ន្ធ តាមរយៈនីតិវិធីសមស្រប ហើយជាពិសេសតាមរយៈស្ថាប័ន តំណាងរបស់ខ្លួន នៅពេលណាដែលមានការគិតគូដល់វិធានការផ្លូវច្បាប់ ឬរដ្ឋបាលដែលអាចប៉ះពាល់ដល់ពួកគេ ។

ខ-បង្កើតមធ្យោបាយដែលតាមរយៈនេះ ប្រជាជនទាំងនេះអាចចូលរួមដោយសេរី យ៉ាងហោចណាស់អាច ចូលរួមដូចគ្នានឹងប្រជាពលរដ្ឋផ្សេងទៀតដែរ នៅគ្រប់កំរិតនៃការធ្វើសេចក្តីសម្រេចចិត្ត ក្នុងស្ថាប័នដែលកើតចេញពីការបោះឆ្នោត និងស្ថាប័នរដ្ឋបាល និងអង្គភាពផ្សេងៗទៀតដែលទទួលខុសត្រូវលើគោលនយោបាយ និងកម្មវិធីដែលពាក់ព័ន្ធដល់ពួកគេ ។

គ- បង្កើតមធ្យោបាយ ដើម្បីឱ្យមានការអភិវឌ្ឍន៍ពេញលេញនូវស្ថាប័ន និងគំនិតផ្តួចផ្តើមផ្ទាល់ពីប្រជាជនទាំងនេះ ហើយក្នុងករណីសមស្រប ត្រូវផ្តល់ធនធានចាំបាច់សំរាប់គោលបំណងនេះ ។

២- ការពិគ្រោះយោបល់ដែលត្រូវធ្វើក្នុងការអនុវត្តន៍អនុសញ្ញានេះ ត្រូវអនុវត្តដោយសុចរិត និងតាមទំរង់ សមស្របទៅតាមកាលៈទេសៈ ដោយមានទិសដៅសម្រេចបាននូវការយល់ព្រម ឬឆន្ទៈព្រមព្រៀង ចំពោះវិធានការដែលបានស្នើឡើង ។

**មាត្រា ៧**

១-ប្រជាជនពាក់ព័ន្ធត្រូវមានសិទ្ធិសម្រេចអំពីអាទិភាពរបស់ខ្លួនសំរាប់កិច្ចដំណើរការអភិវឌ្ឍន៍ ក្នុងករណីដែលមានការប៉ះពាល់ដល់ជីវភាពរស់នៅ ជំនឿ ស្ថាប័ន និងសុខមាលភាពផ្នែកស្មារតីរបស់ពួកគេ និងដីធ្លីដែល ពួកគេកាន់កាប់ ឬប្រើប្រាស់ និងប្រើសិទ្ធិគ្រប់គ្រង តាមដែលអាចធ្វើទៅបាន លើការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ផ្ទាល់ខ្លួន ។ ក្រៅពីនេះ ពួកគេត្រូវចូលរួមក្នុងការរៀបចំបង្កើត ការអនុវត្តន៍ និងការវាយតម្លៃលើផែនការ និងកម្មវិធីអភិវឌ្ឍន៍ជាតិ និងតំបន់ ដែលអាចប៉ះពាល់ដល់ខ្លួនផ្ទាល់ ។

២-ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌជីវភាព និងការងារ និងកំរិតនៃសុខភាព និងការអប់រំប្រជាជនពាក់ព័ន្ធ ដោយមានការចូលរួម និងការសហការពីពួកគេ ត្រូវចាត់ជាបញ្ហាអាទិភាពនៅក្នុងផែនការសំរាប់ការ អភិវឌ្ឍន៍សេដ្ឋកិច្ចទូទៅ នៅក្នុងតំបន់ដែលពួកគេតាំងទីលំនៅ ។ គំរោងពិសេសសំរាប់ការអភិវឌ្ឍន៍ក្នុង តំបន់នោះ ត្រូវរៀបចំជំរុញការអនុវត្តន៍ឱ្យបានប្រសើរឡើងថែមទៀត ។

៣-ប្រសិនជាចាំបាច់ រដ្ឋាភិបាលត្រូវធានាឱ្យមានការសិក្សាស្រាវជ្រាវ ដោយសហការជាមួយប្រជាជនពាក់ព័ន្ធ ដើម្បីវាយតម្លៃអំពីផលប៉ះពាល់ផ្នែកសង្គម ស្មារតី វប្បធម៌ និងបរិស្ថានទៅលើពួកគេ ដោយសារសកម្មភាព អភិវឌ្ឍន៍ដែលបានកំណត់នៅក្នុងគំរោងផែនការ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវ ត្រូវចាត់ទុកថាជា លក្ខណៈវិនិច្ឆ័យជាមូលដ្ឋានសំរាប់ការអនុវត្តន៍សកម្មភាពទាំងនេះ ។

៣-រដ្ឋាភិបាលត្រូវចាត់វិធានការ ដោយសហការជាមួយប្រជាជនពាក់ព័ន្ធ ដើម្បីការពារ និងរក្សាបរិស្ថាននៃដែន ដីដែលពួកគេតាំងទីលំនៅ ។

**មាត្រា ៨**

១-ក្នុងការអនុវត្តន៍ច្បាប់ និងលិខិតបទដ្ឋានជាតិនានា ចំពោះប្រជាជនពាក់ព័ន្ធត្រូវគោរពទំនៀមទម្លាប់ ឬច្បាប់ ទំនៀមទម្លាប់របស់ពួកគេ ។

២-ប្រជាជនទាំងនេះមានសិទ្ធិប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ និងស្ថាប័នផ្ទាល់ខ្លួន ដែលការនេះមិនមានវិសមិត ភាពជាមួយនឹងសិទ្ធិជាមូលដ្ឋានដែលកំណត់ដោយប្រព័ន្ធច្បាប់ជាតិ និងជាមួយនឹងសិទ្ធិមនុស្ស ដែលបានទទួលស្គាល់ជាអន្តរជាតិឡើយ។ ត្រូវបង្កើតនីតិវិធី ប្រសិនជាចាំបាច់ ដើម្បីដោះស្រាយវិវាទដែលអាចកើត មានក្នុងការអនុវត្តន៍គោលការណ៍នេះ ។

៣-ការអនុវត្តន៍កថាខ័ណ្ឌ ១ និង ២ នៃមាត្រានេះ មិនត្រូវរារាំងសមាជិក នៃប្រជាជនទាំងនេះមិនឱ្យប្រើប្រាស់ សិទ្ធិដែលផ្តល់ឱ្យពលរដ្ឋទាំងអស់ និងភារកិច្ចប្រហាក់ប្រហែលគ្នានេះឡើយ ។

**មាត្រា ៩**

១-ក្នុងវិសាលភាពដែលស្របទៅនឹងប្រព័ន្ធច្បាប់ជាតិ និងសិទ្ធិមនុស្សដែលបានទទួលស្គាល់ជាអន្តរជាតិ ត្រូវគោរពវិធីសាស្ត្រដែលប្រជាជនពាក់ព័ន្ធអនុវត្តតាមទំនៀមទម្លាប់សំរាប់ ដោះស្រាយបទល្មើសដែល សមាជិករបស់ខ្លួនបានប្រព្រឹត្ត។

២-ទំនៀមទម្លាប់ពាក់ព័ន្ធនឹងរឿងព្រហ្មទ័ណ្ឌរបស់ប្រជាជនទាំងនេះ អាជ្ញាធរ និងតុលាការជាអ្នកត្រូវគិតគូរដោះស្រាយ ។

**មាត្រា ១០**

១-ក្នុងការដាក់ទោសព្រហ្មទ័ណ្ឌដូចមានចែងក្នុងច្បាប់ទូទៅ ដល់សមាជិកនៃប្រជាជនទាំងនេះ ត្រូវគិតគូរអំពី ចរិតលក្ខណៈផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ពួកគេ ។

២-ត្រូវប្រើប្រាស់វិធីសាស្ត្រផ្សេងៗនៃការដាក់ទណ្ឌកម្ម ជំនួសអោយការដាក់បង្ខាំងនៅក្នុងពន្ធនាគារ ។

**មាត្រា ១១**

ការទាមទារពីសមាជិកនៃប្រជាជនពាក់ព័ន្ធឱ្យផ្តល់ ដោយមិនអាចខានបាននូវការធ្វើការងារដោយបង្ខំ ទោះក្នុងរូបភាពណាក៏ដោយ ដោយផ្តល់ ឬមិនផ្តល់ប្រាក់ឈ្នួល ត្រូវបានហាមឃាត់ និងត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ លើកលែងតែករណីមួយចំនួន ដូចមានចែងក្នុងច្បាប់សំរាប់ពលរដ្ឋទាំងអស់ ។

**មាត្រា ១២**

ប្រជាជនពាក់ព័ន្ធត្រូវបានធានាការពារមិនឱ្យមានការរំលោភបំពានលើសិទ្ធិ

របស់ខ្លួន ហើយត្រូវមានលទ្ធភាពដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់ដោយបុគ្គលម្នាក់ៗ ឬតាមរយៈស្ថាប័នតំណាងរបស់ខ្លួន ដើម្បីការពារសិទ្ធិទាំង នេះប្រកបដោយប្រសិទ្ធិភាព។ ត្រូវចាត់វិធានការមួយចំនួន ដើម្បីធានាឱ្យសមាជិកនៃប្រជាជនទាំងនេះ អាចយល់ និងត្រូវបានគេយល់ច្បាស់អំពីដំណើរការដោះស្រាយរឿងក្តីតាមផ្លូវច្បាប់ បើសិនជាចាំបាច់ ត្រូវផ្តល់ឱ្យមានការបកប្រែ ឬ តាមរយៈមធ្យោបាយមានប្រសិទ្ធិភាពផ្សេងទៀត ។

## ផ្នែកទី ២
## ដីធ្លី

**មាត្រា ១៣**

១-ក្នុងការអនុវត្តនីបទបញ្ញត្តិក្នុងផ្នែកនៃអនុសញ្ញានេះ រដ្ឋាភិបាលត្រូវគោរពសារសំខាន់ពិសេសសំរាប់ វប្បធម៌ និងតម្លៃខាងស្មារតីរបស់ប្រជាជនពាក់ព័ន្ធ អំពីទំនាក់ទំនងរបស់គេជាមួយដីធ្លី ឬដែនដី ឬទាំងពីរ យ៉ាងដែលមាន ដែលពួកគេបានកាន់កាប់ ឬប្រើប្រាស់ ហើយជាពិសេសទិដ្ឋភាពសមូហភាពនៃទំនាក់ទំនង នេះ ។

២-ការប្រើពាក្យ "ដីធ្លី "ក្នុងមាត្រា១៥ និង ១៦ ត្រូវរួមបញ្ចូលនូវគោលគំនិតស្តីពីដែនដី ដែលគ្របដណ្តប់ លើបរិស្ថានសរុបនៃតំបន់ដែលប្រជាជនពាក់ព័ន្ធកាន់កាប់ ឬប្រើប្រាស់ ។

**មាត្រា ១៤**

១-សិទ្ធិកម្មសិទ្ធិ និងភោគៈរបស់ប្រជាជនពាក់ព័ន្ធលើដីធ្លីដែលពួកគេកាន់កាប់តាមប្រពៃណី ត្រូវបានទទួលស្គាល់ ។ ម្យ៉ាងវិញទៀត វិធានការនានាត្រូវធ្វើឡើងក្នុងករណីចាំបាច់ ដើម្បីធានាការពារ សិទ្ធិប្រជាជនពាក់ព័ន្ធ ក្នុងការប្រើប្រាស់ដីធ្លីដែលពួកគេមិនកាន់កាប់ផ្តាច់មុខទាំងស្រុង ប៉ុន្តែជាដីធ្លី ដែលពួកគេបានប្រើប្រាស់សំរាប់ចិញ្ចឹមជីវិត ឬសកម្មភាពជាប្រពៃណីរបស់ខ្លួន ។ ត្រូវមានការយកចិត្តទុកដាក់ជាពិសេស ចំពោះស្ថានភាពរបស់ប្រជាជនពនេចរ និងអ្នកធ្វើកសិកម្ម វិលជុំតាមរូបភាពនេះ ។

២-រដ្ឋាភិបាលត្រូវចាត់វិធានការតាមការចាំបាច់ ដើម្បីកំណត់អត្តសញ្ញាណកម្មដីធ្លីដែលប្រជាជនពាក់ព័ន្ធ កាន់កាប់តាមប្រពៃណី និងដើម្បីធានាបាននូវការការពារប្រកបដោយប្រសិទ្ធិភាពនូវសិទ្ធិកម្មសិទ្ធិ និង ភោគៈរបស់គេ ។

៣-ត្រូវបង្កើតនីតិវិធីក្នុងប្រព័ន្ធច្បាប់ជាតិអោយបានគ្រប់គ្រាន់ ដើម្បីដោះស្រាយការទាមទារដីធ្លីរបស់ ប្រជាជនពាក់ព័ន្ធ។

**មាត្រា ១៥**

១-សិទ្ធិប្រជាជនពាក់ព័ន្ធលើធនធានធម្មជាតិ ដែលជាប់នឹងដីធ្លីរបស់ខ្លួនត្រូវបានការពារជាពិសេស។ សិទ្ធិទាំងនេះរួមបញ្ចូលនូវសិទ្ធិរបស់ប្រជាជនទាំងនេះ ដើម្បីចូលរួមនៅក្នុងការប្រើប្រាស់ ការគ្រប់គ្រង និងការអភិរក្សធនធានទាំងនេះ ។

២-ក្នុងករណីដែលរដ្ឋមានកម្មសិទ្ធិលើធនធានរ៉ែ ឬធនធានក្រោមដី ឬសិទ្ធិលើធនធានដ៏ទៃទៀត ដែលជាប់ នឹងដី រដ្ឋាភិបាលត្រូវបង្កើត ឬរក្សានីតិវិធីដែលតាមរយៈនោះ

Khmer.qxp 8/31/2006 9:59 AM Page 13

៣-គេត្រូវពិគ្រោះយោបល់ជាមួយប្រជាជន ទាំងនេះក្នុងទស្សនៈ ដើម្បីឱ្យដឹងច្បាស់អំពីផលប្រយោជន៍របស់ពួកគេថា វានឹងប៉ះពាល់ក៏រិតណា ឬមិនមានការប៉ះពាល់ទេ មុនចាប់ផ្តើមអនុវត្ត ឬអនុញ្ញាតឱ្យអនុវត្តកម្មវិធីណាមួយ ដើម្បីធ្វើការរុករក ឬធ្វើអាជីវកម្មលើធនធានដែលស្ថិតនៅជាប់នឹងដីធ្លីរបស់គេ ។ តាមដែលអាចធ្វើទៅបាន ប្រជាជនពាក់ព័ន្ធត្រូវ ចូលរួមនៅក្នុងផលចំណេញពីសកម្មភាពនោះ និង ត្រូវទទួលសំណងត្រឹមត្រូវ និងយុត្តិធម៌សំរាប់ការខូចខាតណាមួយដែលពួកគេអាចទទួលរងពីលទ្ធផលនៃសកម្មភាពនោះ ។

**មាត្រា ១៦**

១-ក្រោមកថាខ័ណ្ឌខាងក្រោមនៃមាត្រានេះ ប្រជាជនពាក់ព័ន្ធ មិនត្រូវបានបណ្តេញចេញពីដីធ្លីដែលពួកគេ កាន់កាប់ឡើយ ។

២-ក្នុងករណីដែលមានការចាំបាច់ក្នុងការផ្លាស់ប្តូរទីលំនៅថ្មីសំរាប់ប្រជាជនទាំងនេះទៅតាមវិធានការពិសេសណាមួយ ការផ្លាស់ប្តូរលំនៅថ្មីនោះត្រូវធ្វើឡើងតែនៅក្នុងឆន្ទៈព្រមព្រៀងដោយសេរី និងមានការជូន ដំណឹងច្បាស់លាស់ជាមុនប៉ុណ្ណោះ ។ ក្នុងករណីមិនអាចមានឆន្ទៈព្រមព្រៀងទេ ការផ្លាស់ប្តូរលំនៅថ្មីនោះ ត្រូវធ្វើឡើងតែតាមនីតិវិធីសមស្របដែលបានបង្កើតឡើងដោយច្បាប់ជាតិ និងលិខិតបទដ្ឋាននានាដែលរួមបញ្ចូលទាំងការសាកសួរជាសាធារណៈនៅកន្លែងណាដែលសមស្រប ដែលផ្តល់ឱកាសឱ្យមានភាពជាតំណាងមានប្រសិទ្ធិភាពរបស់ប្រជាជនពាក់ព័ន្ធ ។

៣-ពេលណាដែលមានលទ្ធភាព ប្រជាជនទាំងនេះត្រូវមានសិទ្ធិត្រឡប់មកកាន់កាប់ដីធ្លីប្រពៃណីរបស់ពួកគេ វិញ ខណៈដែលទីកដីសំរាប់តាំងទីលំនៅថ្មីលែងមាន ។

Khmer.qxp 8/31/2006 9:59 AM Page 14

៤-ពេលដែលមិនអាចត្រឡប់មកវិញបានទេ ដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ឬ បើគ្មានកិច្ចព្រមព្រៀងទេ តាមរយៈនីតិវិធីដែលសមស្រប ប្រជាជនទាំងនេះត្រូវបាន ផ្តល់ឱ្យក្នុងគ្រប់ករណីដែលអាចធ្វើបានទាំង អស់នូវដីធ្លីដែលមានគុណភាព និង ឋានៈ ផ្លូវច្បាប់យ៉ាងហោចណាស់ស្មើនឹងដីធ្លីដែលពួកគេកាន់កាប់ពីពេលមុន ដែលសមនឹង ផ្តល់សំរាប់សេចក្តីត្រូវការបច្ចុប្បន្នរបស់ពួកគេ និងការអភិវឌ្ឍន៍ទៅថ្ងៃអនាគត ។ ពេលណាប្រជាជនពាក់ព័ន្ធសម្តែងចេញនូវការពេញចិត្តលើសំណងជាប្រាក់ ឬសំណង ដូចដើមវិញ ពួកគេត្រូវបានសងសំណងនោះវិញ ក្រោមការធានាដែលសមស្រប ។

៥-ហេតុដូច្នេះ មនុស្សដែលត្រូវបានផ្លាស់ប្តូរទីលំនៅថ្មី ត្រូវតែបានសំណងពេញលេញ ចំពោះអ្វីដែលខាតបង់ ឬ ការរងរបួស ។

**មាត្រា ១៧**

១-នីតិវិធី ដែលបានបង្កើតដោយប្រជាជនពាក់ព័ន្ធ សម្រាប់ការផ្លាស់ប្តូរសិទ្ធិលើដីធ្លី ក្នុងចំណោមសមាជិកនៃ ប្រជាជនទាំងនេះត្រូវបានគោរព ។

២-ប្រជាជនពាក់ព័ន្ធត្រូវបានការពិគ្រោះយោបល់ នៅពេលណាដែលមានការគិតគូរ ពិចារណាដល់សមត្ថភាពរបស់គេ ដើម្បីផ្ទេរកម្មសិទ្ធិដីធ្លីទៅអ្នកខាងក្រៅ ឬផ្លាស់ប្តូរ សិទ្ធិរបស់គេទៅខាងក្រៅសហគមន៍របស់ខ្លួន ។

១-ជនណាដែលមិនមែនស្ថិតក្នុងក្រុមប្រជាជនពាក់ព័ន្ធ ត្រូវបានរារាំងមិនឱ្យទាញយក គុណប្រយោជន៍ពី ទំនៀមទម្លាប់របស់គេ ឬយកគុណប្រយោជន៍ពីការខ្វះការយល់ដឹង អំពីច្បាប់ លើផ្នែកនៃសមាជិករបស់គេ ដើម្បីទទួលបានកម្មសិទ្ធិភោគៈ ឬការប្រើប្រាស់ លើដីធ្លីដែលជារបស់ពួកគេឡើយ ។

### មាត្រា ១៨

ត្រូវបង្កើតទោសបញ្ញត្តិគ្រប់គ្រាន់នៅក្នុងច្បាប់ ដើម្បីផ្តន្ទាទោសចំពោះការចូលយក រុករានទន្ទ្រានយក ឬប្រើប្រាស់ដីធ្លីរបស់ប្រជាជនពាក់ព័ន្ធ ហើយរដ្ឋាភិបាលត្រូវចាត់វិធានការ ដើម្បីការពារកុំឱ្យមានបទល្មើសដូច្នោះកើត ឡើង។

### មាត្រា ១៩

កម្មវិធីជាតិបែងចែកដីធ្លីកសិកម្មត្រូវផ្តល់ឱ្យប្រជាជនពាក់ព័ន្ធ ដោយស្មើភាពគ្នាទៅនឹងអ្វីដែលផ្តល់ឱ្យប្រជាពលរដ្ឋទូទៅ ចំពោះ :

ក-ការផ្តល់ដីធ្លីបន្ថែមទៀតដល់ប្រជាជនទាំងនេះ ពេលដែលពួកគេមិនមានដីធ្លីចាំបាច់សំរាប់បំពេញ សេចក្តីត្រូវការចាំបាច់សំរាប់ជីវភាពរស់នៅធម្មតា ឬសំរាប់កំណើនចំនួនសមាជិកដែលអាចកើនឡើង ។

ខ-ការផ្តល់មធ្យោបាយចាំបាច់ ដើម្បីជំរុញការអភិវឌ្ឍន៍ដីធ្លីដែលប្រជាជនទាំងនេះកាន់កាប់រួចហើយ ។

## ផ្នែកទី ៣
## ការជ្រើសរើស និង លក្ខខណ្ឌការងារ

### មាត្រា ២០

១-នៅក្នុងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានជាតិ និងមានកិច្ចសហប្រតិបត្តិការជាមួយប្រជាជនពាក់ព័ន្ធ រដ្ឋាភិបាលត្រូវអនុម័តវិធានការពិសេស ដើម្បីធានាឱ្យមានការការពារប្រកបដោយប្រសិទ្ធិភាពលើការជ្រើសរើស និងលក្ខខណ្ឌការងាររបស់កម្មករ

Khmer.qxp 8/31/2006 9:59 AM Page 16

នៃប្រជាជនពាក់ព័ន្ធ ក្នុងកិរិតមួយដែលពួកគេមិនត្រូវបានការពារ ប្រកបដោយប្រសិទ្ធិភាពដោយច្បាប់ដែលអនុវត្តចំពោះកម្មករទូទៅ ។

២-រដ្ឋាភិបាលត្រូវប្រើប្រាស់គ្រប់លទ្ធភាពដែលអាចធ្វើបាន ដើម្បីការពារកុំឱ្យមានការរើសអើងរវាងកម្មករ ដែលជាប្រជាជនពាក់ព័ន្ធ និងកម្មករផ្សេងៗទៀត ជាពិសេសលើបញ្ហា :

ក-ការទទួលឱ្យធ្វើការងារ រួមទាំងការងារជំនាញ ព្រមទាំងវិធានការនានា ដើម្បីលើកកំពស់ និងការតំ ឡើងឋានៈ

ខ-ការផ្តល់ប្រាក់កំរៃស្មើគ្នាសំរាប់ការងារដូចគ្នា

គ-ការឧបត្ថម្ភសុខភាព និងសង្គមកិច្ច សុវត្ថិភាព និងសុខភាពមុខរបរ អត្ថប្រយោជន៍សន្តិសុខសង្គម ទាំងអស់ និងអត្ថប្រយោជន៍ដែលពាក់ព័ន្ធនឹង-មុខរបរដ៏ទៃទៀត និងកន្លែងស្នាក់នៅ ។

ឃ-សិទ្ធិបង្កើតសមាគម និងសេរីភាពអនុវត្តសកម្មភាពការងារសហជីពស្របច្បាប់ និង សិទ្ធិក្នុងការសម្រេចអនុសញ្ញារួមជាមួយនិយោជក ឬអង្គការនិយោជកនានា ។

៣- វិធានការដែលចាត់នោះ ត្រូវរួមបញ្ចូលនូវវិធានការមួយចំនួន ដើម្បី :

ក-ធានាថាកម្មករដែលជាប្រជាជនពាក់ពន្ធ័ រួមទាំងកម្មករតាមរដូវកាល កម្មករមិនទៀងទាត់ (កម្មករ អណ្តែត) ឬ កម្មករទេសន្តរប្រវេសន៍នៅក្នុងការងារកសិកម្ម ឬការងារដ៏ទៃទៀត ព្រមទាំងជនទាំងឡាយណាដែលត្រូវបានជួលដោយអ្នកម៉ៅការការងារ ទទួលបានការការពារក្រោមច្បាប់ជាតិ និង ការអនុវត្តន៍ ដូចគ្នានឹងកម្មករឯទៀត ក្នុងវិស័យដូចគ្នា និងធានាថា

ពួកគេបានដឹងពេញលេញអំពីសិទ្ធិរបស់ខ្លួនក្រោម នីតិការងារ និងអំពីមធ្យោបាយដោះស្រាយដែលអាចមានចំពោះពួកគេ ។

ខ-ធានាថាកម្មករដែលជាប្រជាជនទាំងនេះ មិនត្រូវស្ថិតក្រោមលក្ខខណ្ឌការងារដែល គ្រោះថ្នាក់ដល់សុខភាពរបស់ខ្លួនឡើយ ជាពិសេសតាមរយៈការធ្វើឱ្យទទួលរងផលប៉ះពាល់ពីថ្នាំសម្លាប់សត្វល្អិត ឬសារធាតុពុលដទៃទៀតឡើយ ។

គ-ធានាថាកម្មករដែលជាប្រជាជនពាក់ព័ន្ធ មិនស្ថិតក្រោមរបៀបរបបជ្រើសរើស ដោយបង្ខំ រួមទាំងការងារកាត់សងបំណុល និងទំរង់ផ្សេងៗទៀតតាមបែបទាសករ បំណុលឡើយ ។

ឃ- ធានាថាកម្មករដែលជាប្រជាជនទាំងនេះ មានឱកាសការងារស្មើគ្នា និងមានការគិតគូយកចិត្តទុកដាក់ ស្មើគ្នាចំពោះបុរស និងស្ត្រី និងការការពារមិនឱ្យមានការយាយីខាងផ្លូវភេទឡើយ ។

៤- ត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការបង្កើតសេវាកម្មអធិការកិច្ចការងារគ្រប់គ្រាន់នៅក្នុងតំបន់ដែលមាន កម្មករដែលជាប្រជាជនពាក់ពន្ធ័ធ្វើការងារទទួលប្រាក់កំរៃដើម្បីធានាឱ្យការអនុវត្តន៍ស្របទៅនឹងបទបញ្ញត្តិ ក្នុងផ្នែកនេះនៃអនុសញ្ញានេះ ។

# ផ្នែកទី ៤
# ការបណ្តុះបណ្តាលវិជ្ជាជីវៈ សិប្បកម្ម និងឧស្សាហកម្មជនបទ

## មាត្រា ២១

សមាជិកនៃប្រជាជនពាក់ព័ន្ធ ត្រូវមានឱកាសយ៉ាងហោចណាស់ស្មើនឹងឱកាសដែលពលរដ្ឋដទៃទៀតមាន ចំពោះការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## មាត្រា ២២

១-ត្រូវចាត់វិធានការ ដើម្បីជំរុញឱ្យមានការចូលរួមដោយស្ម័គ្រចិត្ត ពីសមាជិកប្រជាជនពាក់ព័ន្ធនៅក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសំរាប់ការអនុវត្តន៍ទូទៅ ។

២-នៅពេលណាដែលកម្មវិធីដែលមានស្រាប់នៃការបណ្តុះបណ្តាលវិជ្ជាជីវៈសំរាប់ការអនុវត្តន៍ទូទៅមិនអាច បំពេញបានតាមសេចក្តីត្រូវការរបស់ប្រជាជនពាក់ព័ន្ធទេនោះ រដ្ឋាភិបាលត្រូវ ដោយមានការចូលរួមពី ប្រជាជនពាក់ព័ន្ធ ធានាឱ្យមានការផ្តល់កម្មវិធីបណ្តុះបណ្តាលពិសេស និងសម្ភារៈបរិក្ខានានា ។

៣-កម្មវិធីបណ្តុះបណ្តាលពិសេស ត្រូវផ្អែកលើបរិស្ថានសេដ្ឋកិច្ច លក្ខខណ្ឌសង្គម និងវប្បធម៌ និងសេចក្តីត្រូវ ការជាក់ស្តែងរបស់ប្រជាជនពាក់ព័ន្ធ ។ ការសិក្សាទាំងឡាយណាដែលធ្វើឡើងពាក់ព័ន្ធនឹងបញ្ហានេះ ត្រូវធ្វើឡើងដោយសហការជាមួយប្រជាជនពាក់ព័ន្ធទាំងនេះ តាមរយៈការពិគ្រោះយោបល់ជាមួយពួកគេ អំពីការរៀបចំ និងអនុវត្តន៍កម្មវិធីទាំងនេះ ។ ប្រសិនជាអាចធ្វើទៅបាន ត្រូវអនុញ្ញាតឱ្យប្រជាជនទាំងនេះទទួលខុសត្រូវបន្តិចម្តងៗលើការរៀបចំ និងការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលពិសេសនោះ ប្រសិនបើពួក គេសម្រេចថាអាចធ្វើបាន។

**មាត្រា ២៣**

១-សិប្បកម្ម ឧស្សាហកម្មតាមជនបទនិងមូលដ្ឋាន និងសេដ្ឋកិច្ចសំរាប់តែចិញ្ចឹមជីវិត និង សកម្មភាព ប្រពៃណីរបស់ប្រជាជនពាក់ព័ន្ធ ដូចជាការបរបាញ់ នេសាទ ការដាក់អន្ទាក់ និង ការប្រមូលអនុផល ត្រូវបានទទួលស្គាល់ថាជាកត្តាសំខាន់នៅក្នុងការថែរក្សាវប្បធម៌របស់ពួកគេ និងនៅក្នុងស្វ័យសម្រេចផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍន៍របស់ពួកគេ។ ដោយមានការចូលរួមពីប្រជាជនទាំងនេះ ហើយប្រសិនជាអាច ធ្វើទៅបាន រដ្ឋាភិបាលត្រូវធានាឱ្យមានការពង្រឹង និងការលើកកំពស់ដល់សកម្មភាពទាំងនេះ ។

២-ត្រូវបានផ្តល់ជំនួយសមស្របផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ តាមដែលអាចធ្វើទៅបាន តាមការស្នើសុំពី ប្រជាជនពាក់ព័ន្ធ ដោយគិតគូអំពីបច្ចេកវិទ្យាជាប្រពៃណី និងចរិតលក្ខណៈវប្បធម៌របស់ប្រជាជនទាំងនេះ ព្រមទាំងសារៈសំខាន់នៃការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធម៌ ។

## ផ្នែកទី ៥
## សន្តិសុខសង្គម និង សុខភាព

**មាត្រា ២៤**

ប្រព័ន្ធសន្តិសុខសង្គម ត្រូវបានពង្រីកជាបន្តបន្ទាប់ដល់ប្រជាជនពាក់ព័ន្ធ ហើយអនុវត្តន៍ដោយ គ្មានការរើស អើងប្រឆាំងនឹងពួកគេឡើយ ។

**មាត្រា ២៥**

១-រដ្ឋាភិបាលត្រូវធានាឱ្យមានសេវាកម្មផ្នែកសុខភាពសមរម្យដល់ប្រជាជនពាក់ព័ន្ធ ឬត្រូវផ្តល់ឱ្យប្រជាជន ទាំងនោះនូវធនធានដែលអាចឱ្យពួកគេមានលទ្ធភាពរៀបចំ និងផ្តល់សេវាកម្មទាំងនេះក្រោមការទទួលខុសត្រូវ និងការគ្រប់គ្រងរបស់ខ្លួនផ្ទាល់ ដើម្បីឱ្យគេអាចប្រើប្រាស់បទដ្ឋានកំរិតខ្ពស់បំផុតផ្នែកសុខភាព ផ្លូវកាយ និងផ្លូវចិត្ត ។

២-សេវាសុខភាពត្រូវមានមូលដ្ឋាននៅសហគមន៍ តាមដែលអាចធ្វើទៅបាន។ សេវាកម្មទាំងនេះត្រូវបានធ្វើផែនការ និងគ្រប់គ្រងរដ្ឋបាលដោយសហការជាមួយប្រជាជនពាក់ព័ន្ធ និងយកចិត្តទុកដាក់លើលក្ខខណ្ឌ សេដ្ឋកិច្ច ភូមិសាស្ត្រ សង្គមកិច្ច និងវប្បធម៌របស់គេ ព្រមទាំងការបង្ការោគតាមប្រពៃណី ប្រតិបត្តិការព្យាបាល និងឱសថបុរាណរបស់គេ ។

៣-ប្រព័ន្ធថែរក្សាសុខភាពត្រូវផ្តល់អាទិភាពដំបូងដល់ការបណ្តុះបណ្តាល និងការងាររបស់បុគ្គលិក ផ្នែកសុខភាព សហគមន៍មូលដ្ឋាន និងផ្តោតលើការថែរក្សាសុខភាពបឋម ក្នុងពេលដែលបញ្ច្រៀបទំនាក់ ទំនងរឹងមាំជាមួយកំរិតសេវាថែរក្សាសុខភាពផ្សេងៗទៀត ។

៤-ការផ្តល់សេវាសុខភាពនេះត្រូវសម្របសម្រួលជាមួយវិធានការផ្សេងៗទៀតផ្នែកសង្គមកិច្ច សេដ្ឋកិច្ច និង វប្បធម៌នៅក្នុងប្រទេស ។

# ផ្នែកទី ៦
# ការអប់រំ និងមធ្យោបាយទំនាក់ទំនង

## មាត្រា ២៦

ត្រូវចាត់វិធានការដើម្បីធានាថា សមាជិករបស់ប្រជាជនពាក់ព័ន្ធមានឱកាស ទទួលបានការអប់រំ នៅគ្រប់កំរិតយ៉ាងហោចណាស់ ស្មើនឹងសមាជិកឯទៀតនៃ សហគមន៍ជាតិ ។

## មាត្រា ២៧

១-កម្មវិធីអប់រំ និងសេវាកម្មសម្រាប់ប្រជាជនពាក់ព័ន្ធ ត្រូវបង្កើតឱ្យមាន និងអនុវត្ត ដោយសហការជាមួយពួកគេ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការពិសេស និងត្រូវបញ្ចូល ប្រវត្តិសាស្ត្រ ចំណេះដឹង និងបច្ចេកវិទ្យា របស់ពួកគេ ប្រព័ន្ធតម្លៃរបស់គេ និងបំណង ប្រាថ្នាបន្ថែមទៀត ផ្នែកសង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌របស់ ពួកគេ ។

២-អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាឱ្យមានការបណ្តុះបណ្តាលដល់សមាជិកនៃប្រជាជន ទាំងនេះ និងជំរុញឱ្យ ពួកគេចូលរួមក្នុងការរៀបចំបង្កើត និងអនុវត្តកម្មវិធីអប់រំ ក្នុងគោលដៅ ផ្ទេរការទទួលខុសត្រូវបន្តិច ម្តងៗឱ្យពួកគេអនុវត្តកម្មវិធីទាំងនេះ តាម ដែលអាចធ្វើទៅបាន។

៣-ម្យ៉ាងវិញទៀត រដ្ឋាភិបាលត្រូវទទួលស្គាល់សិទ្ធិរបស់ប្រជាជនទាំងនេះ ក្នុងការ បង្កើតស្ថាប័ន និងគ្រឿង បរិក្ខាអប់រំផ្ទាល់ខ្លួនរបស់ពួកគេ ដោយកំណត់ឱ្យស្ថាប័ននេះ ត្រូវបំពេញ តាមបទដ្ឋានអប្បបរមាដែលបង្កើតឡើង ដោយអាជ្ញាធរមានសមត្ថកិច្ច

ដោយមានការពិគ្រោះយោបល់ជាមួយប្រជាជនទាំងនេះ ។ ត្រូវផ្តល់ធនធានគ្រប់គ្រាន់ដើម្បីសំរេចគោលបំណងនេះ ។

**មាត្រា ២៨**

១-ប្រសិនជាអាចធ្វើទៅបាន ត្រូវបង្រៀនកុមារ ដែលជាប្រជាជនពាក់ព័ន្ធឱ្យចេះអាន និងសរសេរភាសាជន ជាតិដើមភាគតិចរបស់ខ្លួនផ្ទាល់ ឬភាសាដែលពួកគេប្រើទូទៅបំផុត។ ប្រសិនបើកិច្ចការនេះ មិនអាចអនុវត្តបាន អាជ្ញាធរមានសមត្ថកិច្ចត្រូវពិគ្រោះយោបល់ជាមួយប្រជាជនទាំងនេះ ក្នុងគោលបំណងអនុម័ត វិធានការមួយចំនួន ដើម្បីធ្វើឱ្យសម្រេចទិសដៅនេះ ។

២-ត្រូវចាត់វិធានការសមស្របដើម្បីធានាថា ប្រជាជនទាំងនេះមានឱកាស ដើម្បីទទួលបានភាពស្ទាត់ជំនាញ នូវភាសាជាតិ ឬភាសាណាមួយក្នុងចំណោមភាសាផ្លូវការរបស់ប្រទេស ។

៣-ត្រូវចាត់វិធានការ ដើម្បីការពារ និងជំរុញការអភិវឌ្ឍន៍ និងការនិយាយភាសាជនជាតិដើមរបស់ប្រជាជន ពាក់ព័ន្ធ ។

**មាត្រា ២៩**

ការចែករំលែកចំណេះដឹងទូទៅ និងជំនាញដែលអាចជួយឱ្យកុមារនៃប្រជាជនពាក់ព័ន្ធចូល រួមពេញទំហឹង និងស្មើភាពនៅក្នុងសហគមន៍របស់ខ្លួនផ្ទាល់ និងក្នុងសហគមន៍ជាតិ ត្រូវតែជាគោលដៅអប់រំប្រជាជនទាំងនេះ ។

Khmer.qxp 8/31/2006 9:59 AM Page 23

### មត្រា ៣០

១-រដ្ឋាភិបាលត្រូវអនុម័តវិធានការដែលសមស្រប តាមប្រពៃណី និងវប្បធម៌ របស់ប្រជាជនពាក់ព័ន្ធ ដើម្បីឱ្យពួកគេយល់ដឹងអំពីសិទ្ធិ និងភារកិច្ចរបស់ខ្លួន ជាពិសេសអំពីការងារ ឱកាសសេដ្ឋកិច្ច បញ្ហាអប់រំ និង សុខភាព សុខមាលភាពសង្គម និងសិទ្ធិរបស់ខ្លួន ដែលមានចែងក្នុងអនុសញ្ញានេះ ។

២-ប្រសិនជាចាំបាច់ វិធានការនេះត្រូវធ្វើតាមរយៈមធ្យោបាយបកប្រែភាសាជាលាយលក្ខណ៍អក្សរ និងតាមរយៈការប្រើប្រព័ន្ធទូរគមនាគមន៍ផ្សព្វផ្សាយជាភាសាប្រជាជនទាំងនេះ ។

### មាត្រា ៣១

ត្រូវចាត់វិធានការផ្នែកអប់រំ ក្នុងចំណោមផ្នែកទាំងអស់នៃសហគមន៍ជាតិ ហើយជាពិសេសក្នុងចំណោម ផ្នែកទាំងឡាយដែលពាក់ព័ន្ធផ្ទាល់បំផុតជាមួយប្រជាជនពាក់ព័ន្ធ ក្នុងទិសដៅលុបបំបាត់ការប្រកាន់ពូជសាសន៍ដែល អាចមានចំពោះប្រជាជនទាំងនេះ ។ ក្នុងគោលដៅនេះ កិច្ចខិតខំប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាថាសៀវភៅប្រវត្តិសាស្ត្រ និងឯកសារសិក្សាផ្សេងៗទៀត ផ្តល់នូវការពណ៌នាអំពីរូបភាពត្រឹមត្រូវពិតប្រាកដ និងជាព័ត៌មាន នៃសង្គម និងវប្បធម៌របស់ប្រជាជនទាំងនេះ ។

## ផ្នែកទី ៧
## ការទាក់ទង និង កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន

**មាត្រា ៣២**

រដ្ឋាភិបាលត្រូវចាត់វិធានការសមស្រប រួមទាំងតាមរយៈមធ្យោបាយនៃកិច្ចព្រមព្រៀងអន្តរជាតិ ដើម្បី សំរួលដល់ការទាក់ទង និងកិច្ចសហការរវាងជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធឆ្លងកាត់ព្រំដែន រួមទាំង សកម្មភាពនានា ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ស្មារតី និងផ្នែកបរិស្ថាន ។

## ផ្នែកទី ៨
## ការគ្រប់គ្រងរដ្ឋបាល

**មាត្រា ៣៣**

១-អាជ្ញាធររដ្ឋាភិបាលដែលទទួលខុសត្រូវចំពោះបញ្ហាទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ ត្រូវធានាឱ្យមានភ្នាក់ងារ ឬយន្តការសមស្របដទៃទៀត ដើម្បីគ្រប់គ្រងកម្មវិធីនានា ដែលប៉ះពាល់ប្រជាជនពាក់ព័ន្ធ ហើយត្រូវធានាផ្តល់មធ្យោបាយចាំបាច់សម្រាប់ការបំពេញមុខងារដែលបានប្រគល់ឱ្យបានសមស្រប ។

២-កម្មវិធីទាំងនេះត្រូវរួមបញ្ចូល :

ក-ការធ្វើផែនការ ការសម្របសម្រួល ការប្រតិបត្តិ និងការវាយតម្លៃ វិធានការនានាដែលមានចែង ក្នុងអនុសញ្ញានេះ ដោយសហការជាមួយប្រជាជនពាក់ព័ន្ធ ។

ខ-ការដាក់ស្នើវិធានការច្បាប់ ឬវិធានការដទៃទៀតដល់អាជ្ញាធរមានសមត្ថកិច្ច និងការត្រួតពិនិត្យមើលការអនុវត្តន៍វិធានការដែលបានចាត់ឡើង ដោយសហការជាមួយប្រជាជនពាក់ព័ន្ធ។

Khmer.qxp 8/31/2006 9:59 AM Page 25

## ជំពូកទី ៩
## បទបញ្ញត្តិទូទៅ

**មាត្រា ៣៤**

ចរិត និងវិសាលភាពនៃវិធានការដែលត្រូវចាត់ ដើម្បីឱ្យស្របតាមអនុសញ្ញានេះ ត្រូវកំណត់ក្នុងលក្ខណៈ ដែលបត់បែនបានដោយគោរពទៅតាមលក្ខខណ្ឌ ចរិតលក្ខណៈនៃប្រទេសនីមួយៗ ។

**មាត្រា ៣៥**

ការអនុវត្តន៍បទបញ្ញត្តិនៃអនុសញ្ញានេះ មិនត្រូវធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិ និងផលប្រយោជន៍ របស់ប្រជាជនពាក់ព័ន្ធស្របទៅតាមអនុសញ្ញានិងអនុសាសន៍ លិខិតុបករណ៍អន្តរជាតិ សន្ធិសញ្ញា ឬច្បាប់ជាតិ សេចក្តីបង្គាប់ ទំនៀមទំលាប់ ឬកិច្ចព្រមព្រៀងនានាឡើយ ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៣៦**

អនុសញ្ញានេះធ្វើការកែសំរួលឡើងវិញ នូវអនុសញ្ញាស្តីពីប្រជាពលរដ្ឋជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធឆ្នាំ១៩៥៧ ។

**មាត្រា ៣៧**

បន្ទាប់ពីផ្តល់សច្ចាប័នជាផ្លូវការលើអនុសញ្ញានេះរួចហើយ ត្រូវបញ្ជូនទៅអគ្គនាយក នៃការិយាល័យ អង្គការពលកម្មអន្តរជាតិដើម្បីចុះបញ្ជី ។

**មាត្រា ៣៨**

១-អនុសញ្ញានេះត្រូវភ្ជាប់កាតព្វកិច្ចតែជាមួយរដ្ឋសមាជិករបស់អង្គការពលរកម្មអន្តរជាតិ ដែលការផ្តល់សច្ចារប័នរបស់ខ្លួន ត្រូវបានចុះបញ្ជីជាមួយនឹងអគ្គនាយករួចហើយប៉ុណ្ណោះ ។

២-អនុសញ្ញានេះចូលជាធរមានក្នុងរយៈពេលដប់ពីរខែ បន្ទាប់ពីកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នរបស់ ប្រទេសជាសមាជិកចំនួនពីរ ត្រូវបានចុះបញ្ជីជាមួយអគ្គនាយក ។

៣-បន្ទាប់ពីនោះមក អនុសញ្ញានេះត្រូវចូលជាធរមានសំរាប់រដ្ឋសមាជិកណាមួយ ក្នុងរយៈពេលដប់ពីរខែ បន្ទាប់ពីកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នរបស់ខ្លួន ត្រូវបានចុះបញ្ជីរួច ។

**មាត្រា ៣៩**

១-រដ្ឋសមាជិកដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះអាចប្រកាសដកខ្លួនចេញបាន បន្ទាប់ពីការផុតកំណត់ រយៈពេលដប់ឆ្នាំចាប់រាប់ពីកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានលើកដំបូង តាមរយៈការទំនាក់ទំនងទៅអគ្គនាយកនៃការិយាល័យអង្គការពលកម្មអន្តរជាតិសំរាប់ការចុះបញ្ជី ។ ការប្រកាសដកខ្លួន ចេញនេះនឹងត្រូវចូលជាធរមានរយៈពេលមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការប្រកាសចុះបញ្ជីនេះ ។

២-រដ្ឋសមាជិកនីមួយៗដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ ហើយដែលមិនអនុវត្ត សិទ្ធិប្រកាសដកខ្លួន ដូចមានចែងក្នុងមាត្រានេះ នៅក្នុងពេលមួយឆ្នាំក្រោយពេលផុត កំណត់រយៈពេលដប់ឆ្នាំខាងលើ ក្នុងកថាខ័ណ្ឌមុន រដ្ឋសមាជិកនោះនឹងជាប់កាតព្វកិច្ច អនុវត្តរយៈពេលដប់ឆ្នាំបន្តទៀត ហើយបន្ទាប់ពីនោះ អាចប្រកាសដកខ្លួនចេញពី អនុសញ្ញានេះ នៅពេលផុតរយៈពេលដប់ឆ្នាំ នីមួយៗក្រោមលក្ខខណ្ឌ ដូចមាន ចែងក្នុង មាត្រានេះ ។

**មាត្រា ៤០**

១-អគ្គនាយកនៃការិយាល័យអង្គការពលកម្មអន្តរជាតិ ត្រូវជូនដំណឹងទៅរដ្ឋសមាជិក ទាំងអស់ នៃអង្គការពលកម្មអន្តរជាតិអំពីការចុះបញ្ជីលិខិតុករណ៍ផ្តល់សច្ចាប័ន និងការ ប្រកាសដកខ្លួនដែលសមាជិកនៃអង្គការនេះបានដាក់ស្នើមកខ្លួន ដោយរដ្ឋសមាជិក របស់អង្គការនេះ ។

២-នៅពេលជូនដំណឹងទៅរដ្ឋជាសមាជិករបស់អង្គការពលកម្មអន្តរជាតិអំពីការចុះបញ្ជី លិខិតុករណ៍ផ្តល់ សច្ចាប័នលើកទី២ ដែលបានដាក់ស្នើមកខ្លួន អគ្គនាយកត្រូវរំលឹកប្រាប់ រដ្ឋសមាជិក នៃអង្គការនេះអំពីកាល បរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ។

**មាត្រា ៤១**

អគ្គនាយកនៃការិយាល័យអង្គការពលកម្មអន្តរជាតិ ត្រូវទាក់ទងទៅ អគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីធ្វើការចុះបញ្ជីលិខិតុបករណ៍នេះ ស្របតាមមាត្រា ១០២ នៃធម្មនុញ្ញសហប្រជាជាតិ ជាពិសេសការផ្តល់សច្ចាប័ន និងការប្រកាសដកខ្លួនចេញ ត្រូវ ចុះបញ្ជីដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្របតាមបទបញ្ញត្តិនៃមាត្រាមុន ។

**មាត្រា ៩២**

ក្នុងករណីការចាំបាច់ ស្ថាប័នអភិបាលនៃអង្គការពលកម្មអន្តរជាតិ ត្រូវបង្ហាញជូនមហាសន្និសិទទូវរបាយ ការណ៍ស្តីពីកិច្ចដំណើរការនៃអនុសញ្ញានេះ និងត្រូវពិនិត្យមើលសេចក្តីត្រូវការនៃការដាក់ចូលក្នុងរបៀបវារៈនៃ សន្និសិទនូវបញ្ហាការពិនិត្យឡើងវិញទាំងស្រុង ឬផ្នែកខ្លះ ។

**មាត្រា ៩៣**

១-ប្រសិនសន្និសិទអនុម័តអនុសញ្ញាថ្មីមួយដោយពិនិត្យសើរើអនុសញ្ញានេះ ទាំងស្រុង ឬផ្នែកខ្លះ ដូច្នោះអនុ សញ្ញាថ្មីត្រូវចែងផ្សេងពីនេះ ថា :

ក-ការផ្តល់សច្ចាប័នដោយរដ្ឋសមាជិកនៃអនុសញ្ញាពិនិត្យសើរើថ្មីនេះ ត្រូវអនុវត្តតាម គោលការណ៍ច្បាប់ ដែលពាក់ព័ន្ធទៅនិងការប្រកាសដកខ្លួនចេញភ្លាមពីអនុសញ្ញានេះ ថ្វីបើមានបទបញ្ញត្តិនៃមាត្រា៣៩ ខាងលើក៏ដោយ ប្រសិនបើ និង នៅពេលដែល អនុសញ្ញាពិនិត្យសើរើថ្មីនេះបានចូលជាធរមាន ។

ខ-ចាប់ពីកាលបរិច្ឆេទដែលអនុសញ្ញាពិនិត្យសើរើថ្មីចូលជាធរមាន អនុសញ្ញានេះ ត្រូវឈប់បើកឱ្យរដ្ឋ សមាជិកទាំងឡាយផ្តល់សច្ចាប័នទៀតហើយ ។

២-ទោះក្នុងករណីណាក៏ដោយ អនុសញ្ញានេះនៅតែស្ថិតនៅជាធរមានក្នុងទំរង់ និងខ្លឹមសារពិតរបស់វាដដែល សំរាប់រដ្ឋសមាជិកដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ ប៉ុន្តែមិនបានផ្តល់សច្ចាប័នលើអនុសញ្ញា ពិនិត្យ សើរើថ្មី ។

**មាត្រា ៩៤**

អត្ថបទនៃអនុសញ្ញានេះ ជាភាសាអង់គ្លេស និងភាសាបារាំងមានតម្លៃស្មើគ្នា ។

**ចប់**

# International Labour Conference


International Labour Organization
Organisation internationale du Travail
Organizactión Internacional del Trabajo




# Convention 169

## Convention Concerning Indigenous and Tribal Peoples in Independent State

English.qxp 8/31/2006 9:58 AM Page 1

# International Labour Conference

# Convention 169

## Convention Concerning Indigenous and Tribal Peoples in Independent State

**Project to Promote ILO Policy on Indigenous and Tribal Peoples (PRO 169)**

International Labour Office Geneva
Tel: + 41 (0) 22 799 7556
Fax: + 41 (0) 22 799 6344
E-mail: PRO169@ilo.org

**Rights-Based Approach to Indigenous Peoples' Development in Cambodia (ITP)**

Tel.: (855) +23 - 220 817, 994 209
Fax: (855) +23 221 536
Email: sophorn.iloitp@online.com.kh
Phnom Penh, Cambodia

International Labour Conference

Convention 169

# Convention Concerning Indigenous and Tribal Peoples in Independent Countries

*Adopted on 27 June 1989 by the General Conference of the International Labour Organisation at its seventy-sixth session*

*Entry into force: 5 September 1991*

The General Conference of the International Labour Organisation,

Having been convened at Geneva by the Governing Body of the International Labour Office, and having met in its seventy-sixth session on 7 June 1989, and

Noting the international standards contained in the Indigenous and Tribal Populations Convention and Recommendation, 1957, and

Recalling the terms of the Universal Declaration of Human Rights, the International Covenant on Economic, Social and Cultural Rights, the International Covenant on Civil and Political Rights, and the many international instruments on the prevention of discrimination, and

Considering that the developments which have taken place in international law since 1957, as well as developments in the situation of indigenous and tribal peoples in all regions of the world, have made it appropriate to adopt new international standards on the subject with a view to removing the assimilationist orientation of the earlier standards, and

Recognising the aspirations of these peoples to exercise control over their own institutions, ways of life and economic development and to maintain and develop their identities, languages and religions, within the framework of the States in which they live, and

Noting that in many parts of the world these peoples are unable to enjoy their fundamental human rights to the same degree as the rest of the population of the States within which they live, and that their laws, values, customs and perspectives have often been eroded, and

